# យល់ដឹងពីការពិនិត្យអក្ខរកម្មៈ ឪពុកម្ដាយ និងក្រុមគ្រួសារ

ដោយចាប់ផ្តើមក្នុងឆ្នាំសិក្សា 2021-22, មណ្ឌលសិក្សាធិការនីមួយៗនឹងពិនិត្យសិស្សក្នុងថ្នាក់ K-2 រកមើលភាពខ្សោយខាងការអភិវឌ្ឍជំនាញអក្ខរកម្មដែលអាចពាក់ព័ន្ធនឹងវិកលទស្សន៍។

## តើកម្មវិធីពិនិត្យអក្ខរកម្មជាអ្វី?

កម្មវិធីពិនិត្យការសិក្សាគឺជាៈ

- ការធ្វើតេស្តខ្លះក្រៅផ្លូវការដែលត្រូវបានផ្តល់ឱ្យសិស្សទាំងអស់ដើម្បីកំណត់ថាតើការធ្វើតេស្តបន្ថែមត្រូវការដែរឬអត់
- មិនមែនជាការវាយតម្លៃផ្លូវការសម្រាប់ការពិបាកសិក្សាឡើយ

## ហេតុអ្វីបានជាកូនរបស់ខ្ញុំកំពុងត្រូវបានពិនិត្យ?

- អន្តរាគមន៍មុនពេល និងបន្ថែមកម្លាំងដើម្បីដោះស្រាយការពិបាកអាន គឺជាមធ្យោបាយល្អបំផុតក្នុងការបង្ការ បញ្ហាមុនពេលពីការប្រែជាកាន់តែធ្ងន់ធ្ងរថែមទៀតតាមពេល។
- ដោយមានការកំណត់អត្តសញ្ញាណមុនពេល និងអន្តរាគមន៍មុនពេល សិស្សដែលមានហានិភ័យសម្រាប់ការពិបាកអាន រួមទាំងការលូតលាស់មិនប្រក្រតី អាចទទួលជោគជ័យក្នុងសាលារៀន និងបញ្ចប់ការសិក្សារួចរាល់សម្រាប់មហាវិទ្យាល័យ អាជីពការងារ និងជីវិតស៊ីវិល។

## តើនរណានឹងគ្រប់គ្រងការពិនិត្យនេះ?

- សិស្សគួរតែត្រូវបានពិនិត្យដោយគ្រូៗនៅថ្នាក់រៀនរបស់ពួកគេ។ កុមារខិតខំប្រឹងប្រែងធ្វើការរបស់ពួកគេ នៅពេលពួកគេមានភាពស្រណុកស្រួល និងមានអារម្មណ៍មានសុវត្ថិភាពជាមួយមនុស្សពេញវ័យដែលពួកគេស្គាល់
- ព័ត៌មានដែលគ្រូបង្រៀនស្វែងយល់តាមរយៈការពិនិត្យ នឹងជួយពួកគេធ្វើផែនការការបង្រៀន និងកំណត់ពីពេលដែលតម្រូវឱ្យមានជំនួយបន្ថែម។

## តើជំនាញអ្វីខ្លះគួរតែត្រូវបានត្រួតពិនិត្យ?

វិកលទស្សន៍មើលទៅខុសគ្នាសម្រាប់កុមារម្នាក់ៗ និងគ្រប់វ័យ និងតាមដំណាក់កាលនានា។ វាគឺធម្មតាសម្រាប់មនុស្សដែលមានវិកលទស្សន៍ក្នុងការតស៊ូអានពាក្យដែលមានពីរ ឬច្រើនព្យាង្គ ក៏ដូចជាៈ

- *ការយល់ដឹងពីមូលសទ្ទៈ* សមត្ថភាពក្នុងការស្តាប់ កំណត់អត្តសញ្ញាណ លុប និងប្តូរសំលេងនៃពាក្យនិយាយ
- *ការយល់ដឹងពីសទ្ទវិទ្យាៈ* ចំណេះដឹងពីសំលេងសម្តី ដូចជា ចុងចួន, ចួនអក្សរដើមព្យាង្គ (ពាក្យដែលចាប់ផ្តើមដោយសំលេងដូចគ្នា) ចំនួនពាក្យក្នុងប្រយោគ និងចំនួនព្យាង្គនៅក្នុងពាក្យ។
- *ចំណេះដឹងពីសំលេងអក្សរៈ* ចំណេះដឹងពីសំលេងដែលតំណាងដោយអក្សរក្នុងអក្ខរក្រម។ នេះក៏រួមបញ្ចូលបន្សំនៃអក្សរនានាដែលតំណាងឱ្យសំលេងសម្តី។
- ការដាក់ឈ្មោះស្វ័យប្រវត្តិរហ័ស (Rapid Automatized Naming, RAN)ៈ សមត្ថភាពក្នុងការដាក់ឈ្មោះយ៉ាងរហ័សលើធាតុដែលធ្លាប់ស្គាល់មួយស៊េរី។ នេះរួមបញ្ចូលទាំងអក្សរ លេខ ពណ៌ និងវត្ថុដែលរកឃើញក្នុងថ្នាក់រៀន។

## តើដំណើរការនៃការពិនិត្យមានអ្វីខ្លះ?

ភាពជាដៃគូគ្រួសារ/សាលារៀនគឺចាំបាច់សម្រាប់ភាពជោគជ័យរបស់សិស្ស។
ជំហានដំបូងនៅពេលអ្នកមានក្ដីកង្វល់អំពីវឌ្ឍនភាពកូនរបស់អ្នកគឺការធ្វើការណាត់ជួបដើម្បីនិយាយទៅកាន់គ្រូបង្រៀនដើម្បីពិភាក្សាគ្នា៖

- សាលារៀនគួរតែពិនិត្យការយល់ដឹងមូលសទ្ទរបស់សិស្ស ការយល់ដឹងពីសទ្ទវិទ្យា និងចំណេះដឹងលើសំលេងអក្សរយ៉ាងហោចណាស់ម្ដងក្នុងមួយឆ្នាំ
    - សាលាមត្តេយ្យ៖ ខែមករា
    - ថ្នាក់ទីមួយ និងទីពីរ៖ រដូវស្លឹកឈើជ្រុះ
- សិស្សដែលចុះឈ្មោះចូលរៀនពាក់កណ្ដាលឆ្នាំ គួរតែត្រូវបានពិនិត្យជាមួយមិត្តភក្តិរបស់ពួកគេតាមកាលបរិច្ឆេទពិនិត្យបន្ទាប់។
- សាលារៀនគួរតែពិនិត្យជំនាញដាក់ឈ្មោះស្វ័យប្រវត្តិរហ័សរបស់សិស្សនៅសាលាមត្តេយ្យ និងនៅថ្នាក់ទី 1។
- សិស្សដែលបង្ហាញពីមុខវិជ្ជាខ្សោយតាមកម្មវិធីពិនិត្យដំបូង នឹងទទួលបានការធ្វើអន្តរាគមន៍បន្ថែម ហើយដំណើរការរបស់ពួកគេនឹងត្រូវត្រួតពិនិត្យ។
- គ្រូបង្រៀនដែលគ្រប់គ្រងកម្មវិធីពិនិត្យ នឹងត្រូវបានបណ្ដុះបណ្ដាលឱ្យប្រើប្រាស់ឧបករណ៍ពិនិត្យដោយយោងតាមអនុសាសន៍របស់អ្នកបោះពុម្ពផ្សាយ។
- ក្រុមគ្រួសារនឹងត្រូវចូលរួមធ្វើការសម្រេចចិត្ត និងធ្វើបច្ចុប្បន្នភាពការអនុវត្តរបស់សិស្ស។

## ការយល់ដឹងពីវិកលទស្សន៍៖

- ភាពខុសគ្នាដែលធ្វើឱ្យមានដំណើរការសំលេងសម្ដីមានភាពពិបាក ជាពិសេសសមត្ថភាពក្នុងការស្ដាប់ឮ ជំនួស និងប្ដូរសំលេងមួយៗក្នុងពាក្យនានា។
- បានបង្ហាញលក្ខណៈតាមរយៈបញ្ហាប្រឈមនឹងការអាន និងការប្រកបអក្សរ ជាពិសេសមានបញ្ហាទាក់ទងនឹងតួអក្សរនិងសម្លេង។
- ទំនងជាបង្កឱ្យមានបញ្ហាការសិក្សា និងការចងចាំវាក្យសព្ទ ការយល់ដឹងពីអ្វីដែលបានអាន ការគិតលើក្រដាស។
- មិនពាក់ព័ន្ធនឹងបញ្ហាទូទៅទេ។
- មិនមែនជាបញ្ហាការមើល ឬដែលបណ្ដាលដោយកង្វះការជំរុញទឹកចិត្ត ចំណាប់អារម្មណ៍ ឬការបង្ហាញទៅនឹងអក្សរសាស្ត្រសំបូរបែបឡើយ។

**វីដេអូ៖** *[អ្វីជាវិកលទស្សន៍/វិកលទស្សន៍ត្រូវបានពន្យល់ (Dyslexia/Dyslexia Explained)]* ដោយ Margie Gillis ជាមួយ Understood.org។

## ធនធាននានា

- [ការិយាល័យនាយកនៃការណែនាំសាធារណៈ (Office of Superintendent of Public Instruction, OSPI) វិកលទស្សន៍ ទំព័រ]
- [ការិយាល័យនាយកនៃការណែនាំសាធារណៈ (Office of Superintendent of Public Instruction, OSPI) MTSS ទំព័រ]
- [សំណួរ ចោទសួរ ជារឿយៗ ឯកសារ]
- [ការិយាល័យនាយកនៃការណែនាំសាធារណៈ (Office of Superintendent of Public Instruction, OSPI) ELA ការអនុវត្ត ល្អបំផុត មីនុយ]
- [មជ្ឈមណ្ឌលជាតិនៃការធ្វើឱ្យប្រសើរឡើងអក្ខរកម្ម (National Center of Improving Literacy, NCIL) ឈុតឧបករណ៍]
- [WA សាខា នៃ សមាគមន៍ វិកលទស្សន៍ អន្តរជាតិ (International Dyslexia Association)]